**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សារលិខិតរំលែកទុក្ខ

**ជូនចំពោះ**

**ឯកឧត្តម ឈួន សុធី ព្រមទាំងក្រុមគ្រួសារ**

ឯកឧត្តមជាទីគោរពរាប់អានដ៏ជ្រាលជ្រៅ!

ខ្ញុំ និងភរិយា ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ពិតជាមានក្តីក្តុកក្តួលរន្ធត់ចិត្តឥតឧបមាដោយបានទទួលដំណឹងថា **លោកជំទាវ ឈឹម ប៉ែននីឡា** ត្រូវជាភរិយារបស់ **ឯកឧត្តម** បានទទួលមរណភាព នៅថ្ងៃពុធ ១កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៤ វេលាម៉ោង ១:៣០នាទីរំលងអធ្រាត្រ នៅទីក្រុងបាងកក ប្រទេសថៃ ដោយរោគាពាធ។

ក្នុងឱកាសប្រកបដោយក្តីខ្សឹកខ្សួលរំជួលចិត្ត ដ៏មហាក្រៀមក្រំនេះ ខ្ញុំ និងភរិយា ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមសម្តែងនូវសមានទុក្ខប្រកបដោយអនិច្ចលក្ខណធម៌ ដ៏មហាជ្រាលជ្រៅ ព្រមទាំងក្តីសង្វេគដ៏មហាធំធេង និងពោរពេញដោយក្តីសោកស្តាយស្រណោះអាឡោះអាល័យជាអនេកប្បការចំពោះការបាត់បង់ **លោកជំទាវ ឈឹម ប៉ែននីឡា** ដែលនេះជាការបាត់បង់ភរិយា ម្តាយ ម្តាយក្មេក ម្តាយមីង ជីដូន ជាទីគោរពស្រឡាញ់ដ៏ជ្រាលជ្រៅជាទីបំផុត ប្រកបដោយព្រហ្មវិហារធម៌ និងសង្គហធម៌ ដ៏ល្អប្រពៃរបស់ក្រុមគ្រួសារ ដែលកន្លងមកក្នុងឆាកជីវិតរបស់ **លោកជំទាវ** បានខិតខំតស៊ូចិញ្ចឹមបីបាច់ និងអប់រំទូន្មានបុត្រធីតា រហូតក្លាយជាបញ្ញវន្ត និងជាធនធានមនុស្សដ៏មានតម្លៃសម្រាប់សង្គមជាតិ។

ជាថ្មីម្តងទៀត ខ្ញុំ និងភរិយា ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមលំឱនកាយឧទ្ទិសបួងសួងដល់ដួងវិញ្ញាណក្ខន្ធ **លោកជំទាវ ឈឹម ប៉ែននីឡា** សូមបានទៅសោយសុខក្នុងសុគតិភព កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តម ព្រមទាំងក្រុមគ្រួសារនៃសព** មេត្តាទទួលនូវការចូលរួមរំលែកទុក្ខដ៏ក្រៀមក្រំនេះ និងការស្រឡាញ់រាប់អានយ៉ាងជ្រាលជ្រៅពីយើងខ្ញុំ។

ថ្ងៃព្រហស្បតិ៍ ២កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

**ហេង សួរ**